**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ...៦៦...សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតមជ្ឈមណ្ឌលឥស្លាមភ្នំពេញ ដែលមានទីតាំងស្ថិតនៅលើផ្ទៃដីវិហារឥស្លាម បឹងកក់ អាល់សារកាល់ រាជធានីភ្នំពេញ និងការតែងតាំងសមាសភាពគណៈកម្មការគ្រប់គ្រង

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៤០០/០១៦ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការតែងតាំងលោកឧកញ៉ា សុះ កំរី ជាចាងហ្វាងនៃគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមសំណើរបស់ក្រសួងធម្មការ និងសាសនា និងគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា

### សម្រេច

**ប្រការ១.**_ ត្រូវបានបង្កើតមជ្ឈមណ្ឌលឥស្លាមភ្នំពេញដែលមានទីតាំងស្ថិតនៅលើផ្ទៃដីវិហារឥស្លាមបឹងកក់ អាល់សារកាល់ ភ្នំពេញ ដើម្បីបម្រើវិស័យសង្គមកិច្ច សាសនា អប់រំនិងវិស័យផ្សេងៗ។

**ប្រការ២.**_ ត្រូវបានតែងតាំងសមាសភាពគណៈកម្មការមួយ ដើម្បីគ្រប់គ្រងទីតាំងវិហារឥស្លាមបឹងកក់ អាល់សារកាល់ និងមជ្ឈមណ្ឌលឥស្លាមភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | | ប្រធាន |
| ២. ឯកឧត្តម **អូស្មាន ហាសាន់** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | | អនុប្រធាន |
| ៣. លោកឧកញ៉ា **សុះ អំរី** ចាងហ្វាងគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា | | សមាជិក |
| ៤. ឯកឧត្តម **ហ្សាការីយ៉ា អាដាម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | | សមាជិក |
| ៥. ឯកឧត្តម **ອ៉ាន់ ម៉ាត់** ប្រធានសមាគមឥស្លាមកម្ពុជា | | សមាជិក |
| ៦. ឯកឧត្តម **សុះ មុះសិន** រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | | សមាជិកអចិន្ត្រៃយ៍ |
| ៧. ឯកឧត្តម **ទូនី រ៉សេត** អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | | សមាជិក |

**ប្រការ ៣.**_ គណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រង ចាត់ចែង និងថែរក្សាវិហារ អាល់សារកាល់ភ្នំពេញ
- សម្របសម្រួលស្វែងរក និងទទួលជំនួយពីបណ្តាប្រទេស អង្គការ សមាគមសម្រាប់កសាងគម្រោងនានានៅក្នុងមជ្ឈមណ្ឌលឥស្លាមភ្នំពេញដើម្បីបម្រើដល់ដំណើរការរបស់មជ្ឈមណ្ឌល និងទ្រទ្រង់សហគមន៍ឥស្លាមនៅកម្ពុជា
- រៀបចំថែរក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងវិហារ និងបរិវេណវិហារដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច
- គណៈកម្មការត្រូវធ្វើរបាយការណ៍អំពីវឌ្ឍនភាពការងារជូនរាជរដ្ឋាភិបាល
- អនុវត្តការងារផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៤.**_ - គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារជំនាញតាមការចាំបាច់
- គណៈកម្មការ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីជួយការងារតាមតម្រូវការចាំបាច់
- សមាជិកគណៈកម្មការ- អនុគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ក្នុងករណី ប្រធានអវត្តមាន អនុប្រធាន ជាប្រធានស្តីទី។

**ប្រការ ៥.**_ គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធម្មការ និងសាសនា ក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៦.**_ បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧.**_ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ សីហា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ